# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួង ផែនការ**

លេខ :១៣៧ ប្រក.ផក.

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមេសា ឆ្នាំ ២០១៧

**ប្រកាស**

**ស្តីពី**

**ការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរផែនការរាជធានី ខេត្ត**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ចុះថ្ងៃទី២៤ខែមករាឆ្នាំ១៩៩៦ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញ អនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន។
- បានឃើញ អនុក្រឹត្យលេខ ៧០ អនក្រ/បក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិវិទ្យាសាស្រ្តនិងបច្ចេកវិទ្យា
- យោងតាមការចាំបាច់របស់ក្រសួង

**សម្រេច**

**ជំពូកទី១**

**បទប្បញ្ញត្តិទូទៅ**

**ប្រការ១–**

ប្រកាសនេះមានគោលដៅកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរផែនការរាជធានី ខេត្តនិងការិយាល័យជំនាញនានាចំណុះ មន្ទីរផែនការរាជធានី ខេត្ត សំដៅបង្កើនប្រសិទ្ធិភាពការងារ ។

**ប្រការ២–**

ប្រកាសនេះមានគោលបំណងដូចខាងក្រោមៈ

– បង្កើតនិងកំណត់បេសកកម្ម តួនាទីនិង ភារកិច្ច ការិយាល័យចំណុះមន្ទីរ និងការិយាល័យផែនការស្ថិតិ ក្រុងស្រុក ខណ្ឌដើម្បីធានាទិន្នផលការងារប្រកបដោយប្រសិទ្ធភាព និងគុណភាព ។

**ប្រការ៣.–**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះគ្រប់មន្ទីរផែនការរាជធានី ខេត្ត ក្រោមឱវាទក្រសួងផែនការ។

## ជំពូកទី២

## បេសកកម្ម តួនាទី និងភារកិច្ច របស់មន្ទីរផែនការរាជធានី ខេត្ត

**ប្រការ៤.–**

មន្ទីរផែនការរាជធានី ខេត្ត ត្រូវបានប្រគល់បេសកកម្មឲ្យទទួលបន្ទុកអនុវត្ត និងសម្របសម្រួលសកម្មភាពការងាររបស់ក្រសួងផែនការ ដឹកនាំ គ្រប់គ្រង សម្របសម្រួលលើការងារៈ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ កម្មវិធីវិនិយោគ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ទិន្នន័យមូលដ្ឋាន កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ តាមដានត្រួតពិនិត្យវាយតម្លៃអាហារូបត្ថម្ភ កិច្ចសហប្រតិបត្តិការស្ថិតិការងារពាក់ព័ន្ធនិងប្រជាជននិងការអភិវឌ្ឍ សិក្សាស្រាវជ្រាវពីវិទ្យាសាស្ត្របច្ចេកវិទ្យាសម្រាប់ការងារអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ ។

**ប្រការ៥.–**

មន្ទីរផែនការរាជធានី ខេត្ត ដឹកនាំដោយប្រធាន០១(មួយ) រូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

មន្ទីរផែនការរាជធានី ខេត្ត មានសិទ្ធិប្រើប្រាស់ត្រាដោយឡែកក្នុងការបំពេញភារកិច្ចរបស់ខ្លួន។

**ប្រការ៦.–**

មន្ទីរផែនការរាជធានី ខេត្ត មានតួនាទី និងភារកិច្ច ដូចតទៅៈ

- ធ្វើជាសេនាធិការឱ្យក្រសួងផែនការក្នុងការអនុវត្ត ការសម្របសម្រួល ការគាំទ្របច្ចេកទេសដំណើរការរៀបចំនិងអនុវត្តគោលដៅអភិវឌ្ឍន៍ ផែនការ យុទ្ធសាស្ត្រអភិវឌ្ឍន៍ កម្មវិធីវិនិយោគនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលនិងការកំណត់អាទិភាពសម្រាប់ការអភិវឌ្ឍន៍នៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ ស្របតាមគោលនយោបាយផែនការថ្នាក់ជាតិនិងផែនការថ្នាក់ក្រោមជាតិ ។ រៀបចំចងក្រងបោះពុម្ពឯកសារផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគរួមទាំងឯកសារផ្សេងៗពាក់ព័ន្ធនឹងប្រជាជននិងការអភិវឌ្ឍនិងវិទ្យាសាស្ត្រ បច្ចេកវិទ្យា ។
- បណ្តុះបណ្តាល និង ណែនាំបច្ចេកទេសក្នុងការរៀបចំការអនុវត្ត តាមដានត្រួតពិនិត្យនិងវាយតម្លៃគោលដៅអភិវឌ្ឍន៍ ផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល តាមប្រព័ន្ធវិមជ្ឈការក្នុងក្របខណ្ឌរាជធានី ខេត្តក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ។
- សម្របសម្រួលជាមួយស្ថាប័នរដ្ឋ អង្គការសង្គមស៊ីវិល និង វិស័យឯកជនលើការរៀបចំ និងអនុវត្តគោលដៅអភិវឌ្ឍន៍ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ កម្មវិធីវិនិយោគ និង កម្មវិធីវិនិយោគបីឆ្នាំរំកិលសម្រាប់រយៈពេលវែង មធ្យម និងរយៈពេលខ្លី និងការរៀបចំវេទិកាការអភិវឌ្ឍន៍ខេត្ត ។
- សម្របសម្រួលការអនុវត្តគោលនយោបាយ វិមជ្ឈការ និងវិសហមជ្ឈការ នៃផែនការវិស័យ ផែនការមូលដ្ឋាន និងសម្របសម្រួល គាំទ្រដំណើរការសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ ក្រុង ស្រុក ខណ្ឌ ។
- អនុវត្តនិងសម្របសម្រួលការបណ្តុះបណ្តាល ការប្រមូលទិន្នន័យមូលដ្ឋាន ការរៀបចំចងក្រងផលិតឯកសារព័ត៌មានស្ថានភាព ឯកសារពិន្ទុវិស័យ ឯកសារអត្រាភាពក្រីក្រ និងឯកសារផ្សេងៗទៀត ។

វិភាគទិន្នន័យមូលដ្ឋាននិងកំណត់ចំណាត់ថ្នាក់ភាពក្រីក្រតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់។

- តាមដានការអនុវត្តគម្រោងវិនិយោគនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលនៅថ្នាក់ក្រោមជាតិ ។ ចូលរួមផ្តល់អនុសាសន៍លើរាល់សកម្មភាព នៃកម្មវិធីវិនិយោគបីឆ្នាំរំកិល និងវិនិយោគឯកជនរបស់រាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ។ ចូលរួមដេញថ្លៃរាល់គម្រោងវិនិយោគបីឆ្នាំរំកិលនិង ចុះពិនិត្យជាក់ស្តែងតាមវិធីសាស្ត្រ នៃប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃលើគម្រោងដែលកំពុងអនុវត្ត ឬ គម្រោងបានអនុវត្ត គម្រោងដែលមានការសន្យាគាំទ្រ ព្រមទាំងផ្តល់អនុសាសន៍ពីវឌ្ឍនភាពនៃការអនុវត្តគម្រោង និងវឌ្ឍនភាពនៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលនៅថ្នាក់ក្រោមជាតិ ។
- ប្រមូលទិន្នន័យ ចងក្រងស្ថិតិប្រជាសាស្ត្រ ចងក្រងស្ថិតិបឋមវិស័យសេដ្ឋកិច្ច សង្គមកិច្ច ប្រមូលតម្លៃទំនិញទីផ្សារសម្រាប់កសាងសន្ទស្សន៍ថ្លៃ អត្រាអតិផរណា ប្រមូលទិន្នន័យនិងចងក្រងឯកសារផលិតផលក្នុងស្រុកសរុប(GDP)តាមវិធីសាស្ត្រគណនេយ្យជាតិ ។
- អនុវត្តវិធីសាស្ត្រ នៃការប្រមូលទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ និងរៀបចំរបាយការណ៍ស្ថិតិវិភាគ និងផែនទីស្ថិតិរដ្ឋបាលថ្នាក់ក្រោមជាតិ ។
- ចូលរួមអនុវត្ត និងសម្របសម្រួលការធ្វើជំរឿនប្រជាជន ជំរឿនកសិកម្ម ជំរឿនសហគ្រាស ការធ្វើអង្កេតប្រជាសាស្ត្រ អង្កេតសេដ្ឋកិច្ចសង្គមកិច្ច និងអង្កេតកសិកម្ម និងការអង្កេតផ្សេងៗតាមការកំណត់របស់ក្រសួងផែនការ ។
- សម្របសម្រួល និងធ្វើសហប្រតិបត្តិការជាមួយស្ថាប័នពាក់ព័ន្ធដៃគូរអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងផ្នែកឯកជនលើរាល់សកម្មភាពដែលពាក់ព័ន្ធនឹងបញ្ហាប្រជាជននិងការអភិវឌ្ឍដើម្បីពង្រឹង សមត្ថភាពនិងកែលម្អ តាមរយៈសកម្មភាពបណ្តុះបណ្តាល សិក្ខាសាលា អភិវឌ្ឍន៍សហគមន៍ ។
- តម្លើង ថែទាំ ជួសជុល ប្រព័ន្ធបណ្តាញកុំព្យូទ័រផ្ទៃក្នុង ។ គ្រប់គ្រងការបញ្ជូនការទទួលព័ត៌មាន និងទិន្នន័យពីស្ថាប័នពាក់ព័ន្ធ ធានានូវសុវត្ថិភាពទិន្នន័យក្នុងប្រព័ន្ធស្ថិតិ ផែនការ ។ ការងារអភិវឌ្ឍន៍ប្រព័ន្ធ តម្លើងកម្មវិធីដោយរួមបញ្ចូលទាំងប្រព័ន្ធព័ត៌មានភូមិសាស្ត្រ ការរៀបចំផែនទីស្ថិតិនិងការគ្រប់គ្រងប្រព័ន្ធទិន្នន័យមូលដ្ឋាន អភិវឌ្ឍន៍ផ្នែកទន់ដើម្បីប្រសិទ្ធភាពទិន្នន័យមូលដ្ឋាន។ សិក្សាស្រាវជ្រាវពីវិទ្យាសាស្ត្រនិង បច្ចេកវិទ្យា នៅថ្នាក់ក្រោមជាតិ ។
- ធ្វើរបាយការណ៍អំពីសកម្មភាពការងារជូនក្រសួងផែនការតាមការកំណត់។
- បំពេញមុខងារ និង ភារកិច្ចចាំបាច់ផ្សេងៗទៀតដែលរដ្ឋមន្ត្រីក្រសួងផែនការប្រគល់ជូន។

**ជំពូកទី៣**

**អំពីតួនាទី និងភារកិច្ច របស់ការិយាល័យជំនាញនានាចំណុះមន្ទីរផែនការរាជធានី ខេត្ត**

**ប្រការ៧–**

មន្ទីរផែនការរាជធានី ខេត្ត មានការិយាល័យជំនាញចំណុះចំនួន០៦(ប្រាំមួយ)ដូចខាងក្រោម៖

១.ការិយាល័យ រដ្ឋបាល

២.ការិយាល័យ ផែនការ

៣.ការិយាល័យ ស្ថិតិ

៤.ការិយាល័យ តាមដានត្រួតពិនិត្យ និងវាយតម្លៃ

៥.ការិយាល័យ ប្រជាជន និងការអភិវឌ្ឍ

៦.ការិយាល័យ វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា

ការិយាល័យនិមួយៗដឹកនាំដោយប្រធាន ០១ (មួយ)រូប និង មានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។ នៅតាមក្រុង ស្រុក ខណ្ឌ និមួយៗ មានការិយាល័យផែនការ ស្ថិតិ ក្រុង ស្រុក ខណ្ឌចំណុះមន្ទីរផែនការរាជធានី ខេត្ត ។ ការិយាល័យផែនការ ស្ថិតិ ក្រុង ស្រុក ខណ្ឌដឹកនាំដោយប្រធាន ០១ (មួយ) រូប និង អនុប្រធានមួយចំនួនជាជំនួយការ ។

អង្គការលេខរបស់មន្ទីរផែនការរាជធានីខេត្ត ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៨–**

តួនាទី និងភារកិច្ចរបស់ការិយាល័យជំនាញនីមួយៗចំណុះមន្ទីរផែនការ រាជធានី ខេត្ត មានភារកិច្ចដូចតទៅៈ

**១.ការិយាល័យរដ្ឋបាល**

ការិយាល័យរដ្ឋបាល មានតួនាទី និងភារកិច្ចដូចតទៅ:

**ក.ការងាររដ្ឋបាលទូទៅ**

- ទទួលខុសត្រូវក្នុងការប្រើប្រាស់ រក្សាទុកត្រារបស់មន្ទីរ
- គ្រប់គ្រង ចរាចរ និងបែងចែកលិខិតចេញ ចូល
- គ្រប់គ្រងតម្កល់ទុកឯកសារ លិខិតបទដ្ឋានគតិយុត្តិ និងព័ត៌មាន
- ធ្វើរបាយការណ៍ពីលទ្ធផលការងារតាមកាលកំណត់ និងរៀបចំគម្រោងនានារបស់មន្ទីរ
- រៀបចំសន្និបាត វេទិកា សិក្ខាសាលា ការបណ្តុះបណ្តាល និងការប្រជុំនានា ។
- គេហបាលរក្សាសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ សោភ័ណ្ឌភាព អនាម័យក្នុងអង្គភាព
- ទំនាក់ទំនងការងារសាធារណៈ និងកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជាតិ អន្តរជាតិ សង្គមស៊ីវិល និងវិស័យឯកជនពាក់ព័ន្ធ ។

**ខ.ការងារគ្រប់គ្រងបុគ្គលិក**

- រៀបចំសំណើនៃការរៀបចំធនធានមនុស្សស្របតាមរចនាសម្ព័ន្ធគ្រប់គ្រង ។
- រៀបចំផែនការបណ្តុះបណ្តាលនិងសុក្រិត្យការមន្ត្រីរាជការរបស់មន្ទីរ ។
- គ្រប់គ្រងបុគ្គលិក សំណុំឯកសារ ប័ណ្ណសំគាល់ខ្លួនមន្ត្រីរាជការ និងតាមដានបញ្ជីវត្តមានធ្វើការងាររបស់មន្ត្រីរាជការ ។
- រៀបចំសំណើ តែងតាំង តម្លើងថ្នាក់ តម្លើងឋានន្តរស័ក្តិ ការផ្លាស់ប្តូរ ការលើកទឹកចិត្តមន្ត្រីរាជការ និងការដាក់វិន័យ ។

**គ.ការងារគ្រប់គ្រងហិរញ្ញវត្ថុ**

- បំពេញកិច្ចការផ្នែកថវិការៀបចំ ហិរញ្ញវត្ថុ គណនេយ្យ លទ្ធកម្មសាធារណៈ និងរៀបចំផែនការថវិកាប្រចាំឆ្នាំ ។
- រៀបចំរបាយការណ៍គ្រប់គ្រងថវិកាប្រចាំឆ្នាំរបស់មន្ទីរ ។
- គ្រប់គ្រងចលនទ្រព្យ និងអចលនទ្រព្យ សន្និធិសម្ភារ: និងបញ្ជីសារពើភ័ណ្ឌរបស់មន្ទីរ ។

- បំពេញការងារ និងភារកិច្ចផ្សេងៗទៀតតាមការកំណត់របស់ថ្នាក់ដឹកនាំមន្ទីរ ។

២. ការិយាល័យផែនការ

ការិយាល័យផែនការ មានតួនាទី និងភារកិច្ចដូចតទៅ:

ក.ផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគរាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់

- បណ្តុះបណ្តាលពង្រឹងសមត្ថភាព និង ធ្វើសិក្ខាសាលាផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធ និងការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលថ្នាក់ក្រោមជាតិស្រប តាមគោលនយោបាយផែនការថ្នាក់ក្រោមជាតិ ប្រកាសអន្តរក្រសួង និងសេចក្តីនាំបច្ចេក ទេសស្តីពីការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ ។
- អនុវត្ត និងសម្របសម្រួល រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងកម្មវិធីវិនិ យោគរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ស្របតាមសេចក្តីណែនាំបច្ចេកទេស ស្តីពីការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគថ្នាក់ក្រោមជាតិ ព្រមទាំងផ្សព្វផ្សាយ ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ។
- ប្រមូលព័ត៌មានគម្រោងវិនិយោគថ្នាក់ក្រោមជាតិ បញ្ចូលទិន្នន័យគម្រោងតាមកម្មវិធី(SDP) គ្រប់គ្រងទិន្នន័យគម្រោង ផលិតឯកសារនានាស្តីពីគម្រោងអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ ផ្សព្វ ផ្សាយដល់ស្ថាប័នរដ្ឋ អង្គការសង្គមស៊ីវិល និងវិស័យឯកជនដើម្បីកៀរគរធនធានសម្រាប់ អភិវឌ្ឍន៍មូលដ្ឋាន ។
- សម្របសម្រួល ជាមួយមន្ទីរជំនាញ អង្គការសង្គមស៊ីវិល និងវិស័យឯកជន និងអង្គភាពពាក់ព័ន្ធនានា ដើម្បីប្រមូលព័ត៌មានជាតុចូល រៀបចំសូចនាករសំខាន់ៗសម្រាប់ ជាគោលដៅអភិវឌ្ឍន៍ ទាក់ទងនិងការរៀបចំផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគ និងរៀបចំ សិក្ខាសាលា កិច្ចប្រជុំពិគ្រោះយោបល់ផ្សេងៗសម្រាប់អភិវឌ្ឍន៍ នៅថ្នាក់ក្រោម ជាតិ ។
- ផ្សព្វផ្សាយណែនាំអនុវត្ត និងសម្របសម្រួលបច្ចេកទេសដំណើរលើការបចំវេទិការអភិវឌ្ឍន៍ កិច្ចប្រជុំពិគ្រោះយោបល់ សិក្ខាសាលាសមាហរណកម្មផែនការ ថ្នាក់ក្រុង ស្រុក ខណ្ឌ និង ផ្សព្វផ្សាយលទ្ធផលសមាហរណកម្មផែនការ។
- សហការជាមួយ មន្ទីរនិងអង្គភាពពាក់ព័ន្ធ(រដ្ឋបាលខេត្ត, មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ)ដើម្បី ប្រមូលព័ត៌មានវិនិយោគឯកជន កិច្ចសន្យាកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់រាជធានី ខេត្ត សម្រាប់សិក្សាវិភាគកំនើនសេដ្ឋកិច្ច ជូនរាជធានី ខេត្ត និងក្រសួងផែនការ។
- ចូលរួមក្នុងដំណើរការរៀបចំលក្ខណៈវិនិច្ឆ័យជ្រើសរើសគម្រោងវិនិយោគប្រើប្រាស់ មូល និធិវិនិយោគថ្នាក់ក្រោមជាតិ ។

ខ.ការងារទិន្នន័យមូលដ្ឋាន ក្រុង ស្រុក ឃុំ សង្កាត់ និងភូមិ

- បណ្តុះបណ្តាលនិតិវិធីនៃដំណើរការប្រមូលទិន្នន័យមូលដ្ឋាន និងសម្របសម្រួលដំណើរ ការប្រមូលទិន្នន័យតាមភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ។
- បណ្តុះបណ្តាលការបញ្ចូលទិន្នន័យ និងការផលិតឯកសារព័ត៌មានស្ថានភាព ពិន្ទុវិស័យ

- អគ្រាភាពក្រីក្រ ការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងឯកសារផ្សេងៗទៀត។
- បណ្តុះបណ្តាលពង្រឹងសមត្ថភាព ធ្វើសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីការប្រើប្រាស់ឯកសារព័ត៌មានស្ថានភាព ឯកសារពិន្ទុវិស័យ ឯកសារអត្រាភាពក្រីក្រ ឯកសារអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងឯកសារផ្សេងៗទៀតសម្រាប់ជាឧបករណ៍ នៃការរៀបចំផែនអភិវឌ្ឍន៍ និង កម្មវិធីវិនិយោគថ្នាក់ក្រោមជាតិ និងសម្រាប់គ្រប់គ្រង ការអភិវឌ្ឍន៍មូលដ្ឋាន ។

គ.ការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រ

- រៀបចំផែនការសកម្មភាពអនុវត្តកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅរាជធានី ខេត្ត ។
- ធ្វើសិក្ខាសាលាផ្សព្វផ្សាយ និងបើកវគ្គបណ្តុះបណ្តាលស្តីពីនិតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រដល់មន្ត្រីសម្របសម្រួលកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ មេឃុំ ស្មៀន ក្រុមប្រឹក្សាឃុំ សង្កាត់ និងក្រុមតំណាងភូមិ។
- សម្របសម្រួល ប្រមូលចងក្រងព័ត៌មានអំពីគ្រួសារក្រីក្រ ចំណាត់ថ្នាក់គ្រួសារក្រីក្រ ការថតរូប ការបញ្ចូលទិន្នន័យគ្រួសារក្រីក្រ និងការផលិតប័ណ្ណសមធម៌ ។
- ផ្សព្វផ្សាយព័ត៌មានលទ្ធផលអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងធ្វើបច្ចុប្បន្នភាពទិន្នន័យគ្រួសារក្រីក្រ សម្រាប់តម្រូវការយុទ្ធសាស្ត្រជាតិគាំពារសង្គម មូលនិធិសមធម៌ និងតម្រូវការផ្សេងៗទៀត។

ឃ.ការងារអាហារូបត្ថម្ភ

- សំរបសំរួលជាមួយមន្ទីរពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍នានា អង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធដែលធ្វើការងារពាក់ព័ន្ធនឹងអាហារូបត្ថម្ភ ។
- សិក្សាស្រាវជ្រាវពីកង្វះអាហារូបត្ថម្ភ សេចក្តីត្រូវការ និងបញ្ហាពាក់ព័ន្ធនឹងអាហារូបត្ថម្ភ និងរាយការណ៍ជូនមន្ទីរ និង ក្រសួង ។
- បង្កើនការផ្សព្វផ្សាយ ចំណេះដឹងស្តីពីអាហារូបត្ថម្ភឲ្យបានទូលំទូលាយទូទាំងរាជធានី ខេត្ត

៣.ការិយាល័យស្ថិតិ

ក.ស្ថិតិថ្នាក់ក្រោមជាតិ

- បណ្តុះបណ្តាល ប្រជុំ ធ្វើសិក្ខាសាលាពីវិធីសាស្ត្រ នៃការប្រមូលទិន្នន័យស្ថិតិស្តីពីប្រជាសាស្ត្រ ស្ថានភាពគ្រួសារ និងចរិតលក្ខណៈប្រជាសាស្ត្រដទៃទៀត។
- ប្រមូល និងចងក្រងស្ថិតិថ្នាក់ក្រោមជាតិស្តីពីស្ថិតិវិស័យសេដ្ឋកិច្ច សង្គមកិច្ច ធនធានធម្មជាតិ បរិស្ថាន រដ្ឋបាលសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ បរិយាប័ន្ន សមធម៌ សង្គម។
- ប្រមូលចងក្រងវិភាគ និងបោះពុម្ពផ្សព្វផ្សាយទិន្នន័យស្ថិតិបឋមថ្នាក់រាជធានី ខេត្ត ។
- អនុវត្តវិធីសាស្ត្រនៃការប្រមូលទិន្នន័យស្ថិតិរដ្ឋបាលថ្នាក់ក្រោមជាតិ និងការរៀបចំរបាយការណ៍ស្ថិតិវិភាគ និងផែនទីស្ថិតិថ្នាក់ក្រោមជាតិ ។
- អនុវត្តនិងសម្របសម្រួលដំណើរការប្រមូលទិន្នន័យស្តីពីស្ថិតិប្រជាសាស្ត្ររបស់រាជធានី ខេត្ត និងការរៀបចំចងក្រងបោះពុម្ពផ្សាយស្ថិតិប្រជាសាស្ត្រជូនក្រសួងផែនការ រាជធានី ខេត្ត និងអ្នកពាក់ព័ន្ធ។

- ណែនាំ និងសម្របសម្រួលសកម្មភាពស្ថិតិ និង សហប្រតិបត្តិការការងារស្ថិតិថ្នាក់រាជធានី ខេត្ត ជាមួយស្ថាប័នរដ្ឋ អង្គការសង្គមស៊ីវិល និងវិស័យឯកជន។
- ចងក្រងទិន្នន័យស្ថិតិប្រចាំឆ្នាំសម្រាប់ថ្នាក់រាជធានី ខេត្ត ។

**ខ.សន្ទស្សន៍ថ្លៃ និងគណនេយ្យជាតិ**

- ប្រមូលថ្លៃទំនិញទីផ្សារសម្រាប់កសាងសន្ទស្សន៍ថ្លៃ (CIP) អគ្រាអតិផរណា។
- ការបណ្តុះបណ្តាល ប្រជុំប្រមូលទិន្នន័យតាមវិស័យពាក់ព័ន្ធ ដើម្បីចងក្រងឯកសារផលិតផលក្នុងស្រុកសរុប (GDP) របស់រាជធានី ខេត្ត តាមវិធីសាស្ត្រគណនេយ្យជាតិ។
- ធ្វើសិក្ខាសាលាពិគ្រោះយោបល់ និងបង្ហាញលទ្ធផលផលិតផលក្នុងស្រុកសរុបរបស់រាជ ធានី ខេត្ត និងវឌ្ឍនភាពនៃកំណើនសេដ្ឋកិច្ចខេត្ត និងផ្សព្វផ្សាយ ។
- បោះពុម្ព និងផ្សព្វផ្សាយទិន្នន័យផលិតផលក្នុងស្រុកសរុប (GDP) និងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់(CPI) សំរាប់រាជធានីភ្នំពេញ ។

**គ.អង្កេត និងជំរឿន**

- ចូលរួមអនុវត្ត និងសម្របសម្រួលដំណើរការធ្វើជំរឿនប្រជាជន ជំរឿនកសិកម្ម ជំរឿនសហគ្រាស ការធ្វើអង្កេតប្រជាសាស្ត្រនិងសុខភាព អង្កេតសេដ្ឋកិច្ច សង្គមកិច្ច អង្កេតកសិកម្ម និងការអង្កេតផ្សេងៗតាមការកំណត់របស់ក្រសួងផែនការ។
- សម្របម្រួលដឹកនាំការងារធ្វើជំរឿនអង្កេត ឬសំរង់ពត៌មានស្ថិតិតាមវិស័យ ផ្សេងៗ ។
- បណ្តុះបណ្តាលជំនាញអ្នកជំរឿន និងអង្កេត ។
- ផ្សព្វផ្សាយរាល់ពត៌មានស្ថិតិជូន បណ្តាវិស័យ-មូលដ្ឋាន-អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងអ្នកប្រើប្រាស់។

**៩.ការិយាល័យ តាមដានត្រួតពិនិត្យ និងវាយតម្លៃ**

**ក.តាមដានត្រួតពិនិត្យវាយតម្លៃផែនការអភិវឌ្ឍន៍ និង កម្មវិធីវិនិយោគថ្នាក់ក្រោមជាតិ**

- រៀបចំសិក្ខាសាលាផ្សព្វផ្សាយ បណ្តុះបណ្តាលពង្រឹងសមត្ថភាពប្រជុំតម្រង់ទិសនៅថ្នាក់ក្រោមជាតិស្តីពីលិខិតបទដ្ឋាន និងរៀបចំសេចក្តីណែនាំបច្ចេកទេសតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគថ្នាក់ក្រោមជាតិ ។
- អនុវត្ត និងសម្របសម្រួល ដំណើរការតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគថ្នាក់ក្រោមជាតិ ។ ប្រមូលព័ត៌មានត្រួតពិនិត្យលទ្ធផល និងវាយតម្លៃពីប្រសិទ្ធភាពនៃការអនុវត្តគម្រោងវិនិយោគថ្នាក់ក្រោមជាតិ ។
- តាមដានវឌ្ឍនភាពនៃការសម្រេចបានសូចនាករ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគថ្នាក់ក្រោមជាតិ ដោយសហការ និងសម្របសម្រួលជាមួយបណ្តាមន្ទីរជំនាញ អង្គការសង្គមស៊ីវិលនិងវិស័យឯកជន និងអង្គភាពពាក់ព័ន្ធ ។ សហការជាប្រចាំជាមួយអ្នកអនុវត្តគម្រោងអ្នកផ្តល់មូលនិធិអ្នកទទួលផលជាមួយខ្សែរយៈត្រួតពិនិត្យវាយតម្លៃបណ្តា មន្ទីរនិងមូលដ្ឋាននានា ដើម្បីតាមដានត្រួតពិនិត្យល្បឿននៃការអនុវត្តន៍កម្មវិធីវិនិយោគ។

- រៀបចំរបាយការណ៍វឌ្ឍនភាព នៃការអនុវត្តគម្រោងតាមកម្មវិធីគ្រប់គ្រងទិន្នន័យគម្រោង អភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ(SDP) និង ការអនុវត្តគម្រោងវិនិយោគថ្នាក់ក្រោមជាតិ និងផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ។
- ចូលរួមក្នុងដំណើរការរៀបចំគម្រោង និងការដេញថ្លៃគម្រោងវិនិយោគប្រើប្រាស់ មូលនិធិវិនិយោគថ្នាក់ក្រោមជាតិ ។
- រៀបចំរបាយការណ៍វឌ្ឍនភាព នៃការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគថ្នាក់ក្រោមជាតិ និងផ្តល់យោបល់អំពីផលប៉ះពាល់ នៃការអនុវត្តផែនការអភិវឌ្ឍន៍ ទៅលើការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងការរស់នៅរបស់ប្រជាជនជូនក្រសួងផែនការ រាជធានី និងខេត្ត ។
- ផ្សព្វផ្សាយរបាយការណ៍វឌ្ឍនភាព នៃ ការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគថ្នាក់ក្រោមជាតិ ។

ខ.តាមដានត្រួតពិនិត្យវាយតម្លៃអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងអគ្រោភាពក្រីក្រ

- អនុវត្តនិងសម្របសម្រួលដំណើរការតាមដាន ត្រួតពិនិត្យវាយតម្លៃលើដំណើរការអនុវត្តនិងប្រសិទ្ធិភាពនៃការប្រើប្រាស់ ប័ណ្ណសមធម៌កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ។
- ចុះមូលដ្ឋាន ភូមិ ឃុំ ប្រជុំជាមួយគ្រួសារក្រីក្រ ដើម្បីសិក្សាពីប្រសិទ្ធិភាពនៃការប្រើប្រាស់ប័ណ្ណសមធម៌នៃកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ។
- រៀបចំរបាយការណ៍តាមដានត្រួតពិនិត្យ និង វាយតម្លៃប្រសិទ្ធិភាពនៃការប្រើប្រាស់ប័ណ្ណសមធម៌កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ។
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយលទ្ធផល ស្តីពីការតាមដានត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធិភាពនៃការប្រើប្រាស់ប័ណ្ណសមធម៌កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងការទទួលបានសេវាផ្សេងៗរបស់គ្រួសារក្រីក្រ។

៥.ការិយាល័យ ប្រជាជន និងការអភិវឌ្ឍ

- សម្របសម្រួលនឹងធ្វើសហប្រតិបត្តិការជាមួយស្ថាប័នពាក់ព័ន្ធដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិលនិងផ្នែកឯកជន សិក្សាសកម្មភាពដែលពាក់ព័ន្ធ នឹងបញ្ហាប្រជាជន និងការអភិវឌ្ឍ ដើម្បីពង្រឹងសមត្ថភាព ការកែលម្អតាមរយៈសកម្មភាពបណ្តុះបណ្តាលសិក្ខាសាលាអភិវឌ្ឍន៍សហគមន៍។
- ផ្សព្វផ្សាយ ព័ត៌មានស្តីពីគោលនយោបាយ ផែនការកម្មវិធីទាក់ទងនឹងបញ្ហាប្រជាជននិងការអភិវឌ្ឍ។
- បណ្តុះបណ្តាលនៅថ្នាក់ក្រោមជាតិអំពីបច្ចេកទេសនិងចំណេះដឹងក្នុងការវិភាគត្រួតពិនិត្យតាមដានការបញ្ជ្រាបនិងបង្កើនចំណេះដឹងអំពីទំនាក់ទំនងរវាងបញ្ហាប្រជាជននិងការអភិវឌ្ឍ ។ កំណត់សូចនាករ និងការរៀបចំអភិវឌ្ឍន៍សហគមន៍ក្រីក្រសម្របសម្រួលដើម្បីធ្វើការអភិវឌ្ឍន៍សហគមន៍ក្រីក្រ។

៦.ការិយាល័យ អភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា

ការិយាល័យអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា មានតួនាទីនិងភារកិច្ចដូចខាងក្រោម:

ក-ការងារពង្រឹងមូលដ្ឋានអភិវឌ្ឍន៍វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា

- ចូលរួមរៀបចំផ្សព្វផ្សាយ និងអនុវត្តច្បាប់ បទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រផែនការមេ ផែនការសកម្មភាព កម្មវិធី និងយន្តការសម្រាប់ការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យានៅថ្នាក់ក្រោមជាតិ ។
- ចូលរួមរៀបចំផ្សព្វផ្សាយនិងអនុវត្តគម្រោងអភិវឌ្ឍធនធានមនុស្សជំនាញវិជ្ជាជីវៈ សម្រាប់វិទ្យាសាស្ត្រនិងបច្ចេកវិទ្យាប្រកបដោយប្រសិទ្ធភាពនិងភាពសក្តិសិទ្ធ ។

ខ-ការងារព័ត៌មានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា

- សម្របសម្រួល និងជំរុញការប្រមូលការបញ្ជូន ការទទួលការប្រមូលចងក្រង និងកែច្នៃទិន្នន័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាពីស្ថាប័នពាក់ព័ន្ធ និងធានានូវសុវត្ថិភាពនិន្នន័យ ចូលរួមការធ្វើអង្កេតជំរឿនវិភាគនិងវាយតម្លៃកិច្ចការដែលទាក់ទងនឹងការអភិវឌ្ឍសាស្ត្រនិងបច្ចេកវិទ្យា។
- បណ្តុះបណ្តាល ផ្សព្វផ្សាយ និងជំរុញការប្រើប្រាស់ព័ត៌មានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានៅថ្នាក់ក្រោមជាតិ ។
- សម្របសម្រួល ចងក្រង វិភាគ ធ្វើរបាយកសរណ៍ និង ផ្តល់យោបល់ដើម្បីជំរុញការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ។
- បណ្តុះបណ្តាល ផ្សព្វផ្សាយ និងជំរុញការប្រើប្រាស់ព័ត៌មានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានៅថ្នាក់ក្រោមជាតិ ។
- សម្របសម្រួល ចងក្រង វិភាគ ធ្វើរបាយការណ៍ និងផ្តល់យោបល់ដើម្បីជំរុញការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ។

គ-ការងារសហប្រតិបត្តិការដើម្បីការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា

- សហប្រតិបត្តិការជាមួយនឹងក្រសួង ស្ថាប័ន មន្ទីរជំនាញ និងអង្គភាពពាក់ព័ន្ធ ដើម្បីបង្កើតនិងអភិវឌ្ឍបណ្តាញការងារ និងកិច្ចសហប្រតិបត្តិការវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- ឃោសនា និងផ្សព្វផ្សាយពន្យល់ដល់សាធារណជនពីសារៈសំខាន់ នៃវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ចំពោះការអភិវឌ្ឍជាតិ ជីវភាពប្រជាជន និងជីវភាពគ្រួសារខ្លួនឯងផ្ទាល់ សំដៅឲ្យជាតិទទួលបានការយល់ដឹងការគាំទ្រ និងការចូលរួម ពីសាធារណជន
- សម្របសម្រួលកិច្ចការ និងកៀរគរចំណូល និងធនធានថវិការពីគ្រប់មជ្ឈដ្ឋាន សម្រាប់ការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាដល់មន្ទីរជំនាញ និងអង្គភាពពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិ
- សម្របសម្រួល លើកទឹកចិត្ត រក្សានិងលើកកម្ពស់ស្នាដៃឆ្នើមផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាពីគ្រប់មជ្ឈដ្ឋាន រដ្ឋនិងឯកជន ជាតិនិងអន្តរជាតិ ។

ឃ-ការងារពង្រឹងហេដ្ឋារចនាសម្ព័ន្ធ និងកម្មវិធីការស្រាវជ្រាវនិងអភិវឌ្ឍ

- សិក្សាស្រាវជ្រាវ និងសម្របសម្រួលតម្រូវការ និងការផ្គត់ផ្គង់មជ្ឈមណ្ឌលជំនាញ និងបរិក្ខារស្រាវជ្រាវនិងអភិវឌ្ឍនៅថ្នាក់ក្រោមជាតិ
- សម្របសម្រួលការអនុវត្តកម្មវិធីស្រាវជ្រាវនិងអភិវឌ្ឍនៅថ្នាក់ក្រោមជាតិ ។

- ប្រមូលទិន្នន័យកម្មវិធីស្រាវជ្រាវ និងអភិវឌ្ឍពីមន្ទីរជំនាញ និងស្ថាប័នអនុវត្តកម្មវិធីស្រាវជ្រាវ និងអភិវឌ្ឍនៅថ្នាក់ក្រោមជាតិ និងដើម្បីវិភាគ វាយតម្លៃកំណត់ទិសដៅនិងផ្សព្វផ្សាយ ។
- សម្របសម្រួលជំរុញនិងលើកកម្ពស់ពាណិជ្ជូបនីយកម្មលទ្ធផលនៃការស្រាវជ្រាវនិងអភិវឌ្ឍ។

ង-ការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា

- រៀបចំផែនការសកម្មភាពសម្រាប់អនុវត្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា នៅតាមមន្ទីរជំនាញ និងអង្គភាពថ្នាក់ក្រោមជាតិ ។
- អនុវត្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយផែនការយុទ្ធសាស្ត្រ
- ផែនការមេ ផែនការសកម្មភាព និងកម្មវិធីអភិវឌ្ឍវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នៅថ្នាក់ក្រោមជាតិ ។
- តាមដានត្រួតពិនិត្យ និងវាយតម្លៃលើបុគ្គលនិងស្ថាប័នដែលមានស្នាដៃក្នុងការអភិវឌ្ឍវិទ្យា។
- សាស្ត្រ និងបច្ចេកវិទ្យា និងលើកជាសំណើជូនក្រសួងផែនការ និងចម្លងជូនអគ្គលេខាធិការដ្ឋាន ក.ជ.វ.ប ដើម្បីពិនិត្យ និងការសម្រេចលើកទឹកចិត្ត ។
- ផ្សព្វផ្សាយលទ្ធផលនៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ។

**ប្រការ៩–**

នៅតាមក្រុង ស្រុក ខណ្ឌ និមួយៗចំណុះរាជធានី ខេត្ត មានការិយាល័យ ផែនការ ស្ថិតិក្រុង ស្រុក ខណ្ឌចំណុះមន្ទីរផែនការរាជធានី ខេត្ត ទទួលបន្ទុកអនុវត្ត និង សម្របសម្រួលសកម្មភាពការងាររបស់មន្ទីរផែនការរាជធានី ខេត្ត ដឹកនាំគ្រប់គ្រងសម្របសម្រួលលើការងាររៀបចំ និងអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ផែនការអភិវឌ្ឍន៍កម្មវិធីវិនិយោគបីឆ្នាំរំកិល ស្ថិតិទិន្នន័យមូលដ្ឋានកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ការតាមដានត្រួតពិនិត្យវាយតម្លៃ និងការងារអភិវឌ្ឍន៍របស់ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ។

**ប្រការ១០–**

តួនាទីនិងភារកិច្ចរបស់ការិយាល័យផែនការ ស្ថិតិ ក្រុង ស្រុក ខណ្ឌនៃមន្ទីរផែនការរាជធានី ខេត្ត មានភារកិច្ចអនុវត្តការងារ គាំទ្របច្ចេកទេសលើការអនុវត្តប្រព័ន្ធផែនការ ស្ថិតិជាតិ និងប្រព័ន្ធផែនការ ស្ថិតិរថ្នាក់ក្រោមជាតិ តាមរយៈការប្រគល់ភារកិច្ចបច្ចេកទេសការងារពីក្រសួងផែនការ និងមន្ទីរផែនការរាជធានី ខេត្ត ដូចតទៅ៖

- ទទួលបន្ទុកអនុវត្ត សម្របសម្រួល ការរៀបចំ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។
- អនុវត្ត សម្របសម្រួល បណ្តុះបណ្តាលដំណើរការប្រមូលទិន្នន័យមូលដ្ឋានភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ចងក្រងឯកសារព័ត៌មានស្ថានភាព និងឯកសារផ្សេងៗរបស់ក្រុង ស្រុក ខណ្ឌ។
- អនុវត្ត និងសម្របសម្រួលដំណើរអនុវត្តកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រនិងអគ្រាភាពក្រីក្រក្រុង ស្រុក ខណ្ឌ។
- អនុវត្ត និងសម្របសម្រួលដំណើរការចងក្រងស្ថិតិមូលដ្ឋាន៖(១)ស្ថិតិប្រជាសាស្ត្រ។(២) ស្ថិតិបឋមវិស័យសេដ្ឋកិច្ច សង្គមកិច្ច តម្លៃទំនិញទីផ្សារ ស្ថិតិថ្នាក់ក្រោមជាតិ និងចូលរួមអនុវត្តការងារអង្កេត និងជំរឿនផ្សេងៗ។

- អនុវត្តនិងសម្របសម្រួលដំណើរការតាមដានត្រួតពិនិត្យវាយតម្លៃការអនុវត្តគម្រោង និងការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ កម្មវិធីវិនិយោគ ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។
- តាមដានត្រួតពិនិត្យវាយតម្លៃការអនុវត្តកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងប្រសិទ្ធិភាពប្រសិទ្ធផលនៃការប្រើប្រាស់ប័ណ្ណសមធម៌។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**ប្រការ១១–**

ប្រកាសនេះជំនួសឲ្យប្រកាសលេខ២៣២ ផក/ប្រ.ក ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់មន្ទីរផែនការ ខេត្ត ក្រុង ។

**ប្រការ១២–**

ឯកឧត្តម លោក ជំទាវ លោក លោកស្រី ប្រធានអង្គភាពក្រោមឱវាទក្រសួងមានភារកិច្ចអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងផែនការ

ឆាយ ថន

កន្លែងទទួល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- សាលារាជធានី ខេត្ត
- ដូចក្នុងប្រការ ១២
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសនៃប្រកាសលេខ ១៣៧ ប្រក.ផក ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ២០១៧

អង្គការលេខរបស់មន្ទីរផែនការ រាជធានី ខេត្ត

